# Monthly Report Volume 47

November 2025

## Project Activities in November:

- 10th : Monthly Meeting with JICA HQ / Cambodia Office (online)
- 12th–13th : INSET in BTB (Nursing Process Application & Nursing Research)
- 21st: Trainer meeting for Nursing Management & Leadership (Online)
- 23rd –29th : Dispatch of Nursing Education Short-Term Expert
- 26th : Meeting with KC PHD Director
- 26th–27th : INSET in KC (Nursing Ethics & Nursing Management & Leadership)

## INSET in Battambang: Building Local Training Capacity

The third round of In-Service Training (INSET) was successfully conducted in Battambang Province, marking steady progress since the training program began in September. This session brought together 27 nurses for the Nursing Process Application (NPA) course and 20 for the Nursing Research (NR) course, demonstrating strong engagement among local health providers.

The INSET program in this province is gradually becoming locally driven. Under the leadership of the Provincial Training Management Team (PTMT), training support staff from the Provincial Health Department (PHD) and Operational Districts (ODs) are working closely together to manage the entire training cycle. This includes preparing venues and materials, facilitating sessions, supporting trainers and trainees, evaluating results, and compiling reports. While some project support is still needed, the provincial team is increasingly capable of carrying out these tasks independently.

Collaboration and teamwork have been central to this progress. PTMT members and support staff clearly understand their roles and perform them effectively, leading to smoother preparation, facilitation, and participant support compared with earlier rounds.

The improvements observed in Battambang represent a meaningful step toward establishing a sustainable, province-led training system. As the team continues to gain practical experience, further strengthening of planning, preparation, and overall training management is expected in the coming months.



Nursing Research Course Activity



Nursing Research Course Participants



Nursing Process Application Course Participants



Small groups discussion (NPA)

## Implementation of Second INSET Session for Nurses in Kampong Cham

The second In-Service Training (INSET) for nurses in Kampong Cham Province (KC) was held from 26th to 27th, covering two courses: Nursing Ethics (1.5 days, 31 participants) and Nursing Management & Leadership (2 days, 34 participants) at the provincial hospital.

The opening ceremony was presided over by Assist. Prof. Dr. Touch Sokneang, Director of the Human Resource Development Department and the Project Manager, H.E. Dr. Kimsour Phirun, Director of KC PHD, and attended by Assist. Prof. Mr. Thann Sovandeth, Deputy Director of KC Provincial Hospital, as well as Ms. Omachi Mayumi, Short-Term Expert from JICA HQ, Japan.

After the opening, participants were assigned to their designated rooms by the PTMT, and sessions proceeded according to schedule. Dr. Touch Sokneang conducted monitoring and observed both courses on the first day. Ms. Omachi also attended both training courses and provided technical advice from a nursing education perspective, based on her extensive professional experience, particularly regarding training implementation and management.

To enhance training quality, Dr. Touch Sokneang and project staffs met with the PHD Director to discuss venues, lead trainers, trainee arrangements, and provincial staff support. The meeting was successful, with strong cooperation from the leadership.

Compared to the first round, the PTMT showed improved preparation and facilitation, demonstrating steady progress in transferring training management responsibilities from the project to the provincial team. Both courses were successfully completed, with positive feedback from participants.



Opening Ceremony at Kampong Cham Provincial Hospital

## UPCOMING ACTIVITIES IN DECEMBER

- 1st : Intern of Nagasaki Univ. MPH course joining with the team
- 8th : Trainer meeting for Nursing Informatics (Online)
- 10th–11th : INSET in BTB (Quality Improvement and Patient Safety & Nursing Informatic)
- 15th : Monthly Meeting with JICA HQ / Cambodia Office (online)
- 19th : TOT National wide meeting
- 24th : 7th JCC Meeting
- 25th : Nursing Education Long Term Expert Joining the team

## CONTACT INFORMATION


**Email:** info@jicastrings.com

**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh


Scan here to find out more about us:

JICA's FB Page

Project's Homepage

## សកម្មភាពគម្រោងប្រចាំខែវិច្ឆិកា៖

- ថ្ងៃទី១០៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១២ ដល់ទី១៣៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តបាត់ដំបង វគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំជំងឺ និងវគ្គការស្រាវជ្រាវផ្នែកថែទាំ
- ថ្ងៃទី២១៖ កិច្ចប្រជុំគ្រូបង្គោលសម្រាប់មុខវិជ្ជាការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ (តាមប្រព័ន្ធអនឡាយ)
- ថ្ងៃទី២៣ ដល់ថ្ងៃទី២៩ ខែវិច្ឆិកា ៖ អ្នកជំនាញផ្នែកអប់រំការថែទាំចូលរួមក្នុងសកម្មភាព គម្រោងរយៈពេលខ្លី
- ថ្ងៃទី២៦ ៖ កិច្ចប្រជុំជាមួយឯកឧត្តមប្រធានមន្ទីរសុខាភិបាលខេត្តកំពង់ចាម
- ថ្ងៃទី២៦ ដល់ទី២៧៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តកំពង់ចាម វគ្គសីលធម៌ នៃការថែទាំ និងវគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ

## វគ្គបណ្តុះបណ្តាល (INSET) នៅខេត្តបាត់ដំបង៖ ការកសាងសមត្ថភាពបណ្តុះបណ្តាលថ្នាក់មូលដ្ឋាន

វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារ (INSET) សម្រាប់គិលានុបដ្ឋាក នៅខេត្តបាត់ដំបង ជាលើកទី៣ ត្រូវបានធ្វើឡើងដោយជោគជ័យ ដោយកត់សម្គាល់ពីការរីកចម្រើនជាលំដាប់ចាប់តាំងពីកម្មវិធីបណ្តុះបណ្តាលបានចាប់ផ្តើមនៅក្នុងខែកញ្ញា។ វគ្គការប្រើប្រាស់ដំណើរការ នៃការថែទាំជំងឺ (NPA) មានសិក្ខាកាមចូលរួម ២៧នាក់ និងវគ្គការស្រាវជ្រាវផ្នែកថែទាំ (NR) មានសិក្ខាកាមចូលរួម ២០នាក់ ដែលបង្ហាញពីការចូលរួមយ៉ាងខ្លាំងក្លាក្នុងចំណោមអ្នកផ្តល់សេវាសុខភាពថ្នាក់មូលដ្ឋាន។

វគ្គបណ្តុះបណ្តាល INSET នៅថ្នាក់ខេត្តនេះកំពុងតែបញ្ជៀបជាបណ្តើរៗទៅថ្នាក់មូលដ្ឋាន។ ក្រោមការដឹកនាំរបស់ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត (PTMT) មន្ត្រីសម្របសម្រួលការបណ្តុះបណ្តាលមកពីមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត (PHD) និងស្រុកប្រតិបត្តិ (ODs) កំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្នា ដើម្បីគ្រប់គ្រងវគ្គបណ្តុះបណ្តាលទាំងមូល។ កិច្ចការទាំងនេះរួមបញ្ចូលទាំងការរៀបចំទីកន្លែង និងសម្ភារៈសម្រាប់វគ្គបណ្តុះបណ្តាល ការសម្របសម្រួលដល់គ្រូបណ្តុះបណ្តាល និងសិក្ខាកាម លទ្ធផលនៃការវាយតម្លៃ និងការចងក្រងរបាយការណ៍វគ្គបណ្តុះបណ្តាល។ ដោយមានការជួយគាំទ្រការងារមួយចំនួនពីគម្រោង ក្រុមការងារថ្នាក់ខេត្តមានលទ្ធភាពកាន់តែខ្លាំងឡើងក្នុងការអនុវត្តការងារទាំងនេះដោយឯករាជ្យ

កិច្ចសហការ និងការធ្វើការងារជាក្រុមគឺជាចំណុចសំខាន់នៃវឌ្ឍនភាពនេះ។ សមាជិកក្រុម PTMT និងមន្ត្រីសម្របសម្រួលយល់យ៉ាងច្បាស់អំពីតួនាទីរបស់ពួកគេ និងអនុវត្តការងារយ៉ាងមានប្រសិទ្ធភាព ដែលនាំឱ្យការរៀបចំ ការសម្របសម្រួល និងការគាំទ្រពីអ្នកចូលរួមធ្វើឱ្យការរៀបចំវគ្គបណ្តុះបណ្តាលកាន់តែរលូនបើធៀបទៅនឹងវគ្គមុនៗ។

ការកែលម្អដែលបានសង្កេតឃើញនៅខេត្តបាត់ដំបង គឺជាជំហានសំខាន់មួយក្នុងការកសាងប្រព័ន្ធបណ្តុះបណ្តាលឲ្យមានចីរភាពដែលដឹកនាំដោយខេត្ត។ ក្នុងខណៈដែលក្រុមការងារបន្តទទួលបានបទពិសោធន៍អនុវត្តន៍ ការកែលម្អបន្ថែមទៀតចំពោះការធ្វើផែនការ ការរៀបចំ និងការគ្រប់គ្រងការបណ្តុះបណ្តាលទូទៅ គ្រោងនឹងកើតមានឡើងបន្ថែមទៀតក្នុងខែខាងមុខនេះ។


Nursing Research Course Activity


Nursing Research Course Participants


Nursing Process Application Course Participants


Small groups discussion (NPA)

## ការអនុវត្តវគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ជាលើកទី២ នៅខេត្តកំពង់ចាម

វគ្គបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) នៅខេត្តកំពង់ចាម ជាលើកទី២ បានធ្វើឡើងថ្ងៃទី២៦ ដល់ថ្ងៃទី២៧ ដោយបានរៀបចំឡើងចំនួន២វគ្គ គឺ វគ្គសីលធម៌ នៃការថែទាំ (រយៈពេល១ថ្ងៃកន្លះ មានសិក្ខាកាមចូលរួម ៣១នាក់) និងវគ្គការគ្រប់គ្រងការថែទាំ និងភាពជាអ្នកដឹកនាំ (រយៈពេល២ថ្ងៃ មានសិក្ខាកាមចូលរួម ៣៤នាក់)។ វគ្គទាំងពីរនេះបានធ្វើឡើងនៅមន្ទីរពេទ្យខេត្តកំពង់ចាម។

ពិធីបើកវគ្គបណ្តុះបណ្តាលត្រូវបានធ្វើឡើងក្រោមអធិបតីភាព លោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងជាប្រធានគ្រប់គ្រង និងសម្របសម្រួលគម្រោង ឯកឧត្តម វេជ្ជបណ្ឌិត គឹម សួរ ភីរុណ ប្រធានមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តកំពង់ចាម ពិធីនេះក៏មានការអញ្ជើញចូលរួមពីលោកសាស្ត្រាចារ្យជំ. ថាន់ សុវណ្ណដេត នាយករងមន្ទីរពេទ្យខេត្តកំពង់ចាម និងលោកស្រី Omachi Mayumi អ្នកជំនាញការរយៈពេលខ្លីមកពីទីស្នាក់ការកណ្តាល JICA នៃប្រទេសជប៉ុន។

បន្ទាប់ពីកម្មវិធីបើកបានបញ្ចប់ សិក្ខាកាមទាំងអស់ បានបែងចែកទៅតាមបន្ទប់ដែលកំណត់ដោយក្រុម PTMT ហើយវគ្គបណ្តុះបណ្តាលដំណើរការទៅតាមកាលវិភាគដែលបានកំណត់។ នៅថ្ងៃដំបូងនៃវគ្គ លោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង បានចុះត្រួតពិនិត្យ និងសង្កេតមើលវគ្គនីមួយៗផងដែរ។ លោកស្រី Omachi ក៏បានចូលរួមវគ្គបណ្តុះបណ្តាលទាំងពីរ និងផ្តល់ដំបូន្មានបច្ចេកទេសពីទស្សនៈវិស័យអប់រំការថែទាំ ដោយផ្អែកលើ បទពិសោធន៍វិជ្ជាជីវៈដ៏ទូលំទូលាយរបស់គាត់ ជាពិសេសទាក់ទងនឹងការអនុវត្ត និងការគ្រប់គ្រងការបណ្តុះបណ្តាល។

ដើម្បីបង្កើនគុណភាព នៃការបណ្តុះបណ្តាល លោកស្រីសាស្ត្រាចារ្យជំ. ទូច សុខនាង និងបុគ្គលិកគម្រោង បានជួបជាមួយនឹងឯកឧត្តមប្រធានមន្ទីរសុខាភិបាល ដើម្បីពិភាក្សាអំពីទីកន្លែងបណ្តុះបណ្តាល ការចាត់តាំងគ្រូបណ្តុះបណ្តាល ការរៀបចំសិក្ខាកាមចូលរួមវគ្គ និងមន្ត្រីសម្របសម្រួលការបណ្តុះបណ្តាលថ្នាក់ខេត្ត។ កិច្ចប្រជុំនេះទទួលបានជោគជ័យដោយមានការសហការយ៉ាងខ្លាំងពីថ្នាក់ដឹកនាំ។

ក្រុមការងារគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់ខេត្ត (PTMT) បានបង្ហាញពីការរៀបចំ និងការសម្របសម្រួលកាន់តែប្រសើរឡើង បើប្រៀបធៀបទៅនឹងវគ្គលើកទី១ ដោយឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃការទទួលខុសត្រូវរបស់ថ្នាក់ខេត្តក្រោយការប្រគល់ការគ្រប់គ្រងការបណ្តុះបណ្តាលពីគម្រោងទៅក្រុមការងារថ្នាក់ខេត្ត។ វគ្គបណ្តុះបណ្តាលទាំងពីរនេះ ត្រូវបានបញ្ចប់ដោយជោគជ័យដោយមានមតិវិជ្ជមានពីសិក្ខាកាមចូលរួមទាំងអស់។


Opening Ceremony at Kampong Cham Provincial Hospital

## សកម្មភាពនាពេលខាងមុខក្នុងខែធ្នូ

- ថ្ងៃទី១៖ អ្នកហាត់ការមកពីសកលវិទ្យាល័យ Nagasaki បានចូលរួមជាមួយគម្រោង
- ថ្ងៃទី៨៖ កិច្ចប្រជុំគ្រូបណ្តុះបណ្តាលសម្រាប់មុខវិជ្ជា ព័ត៌មានវិទ្យានៃការថែទាំ (តាមប្រព័ន្ធអនឡាយ)
- ថ្ងៃទី១០ ដល់ទី១១៖ ការបណ្តុះបណ្តាល INSET ក្នុងខេត្តបាត់ដំបង
  វគ្គការលើកកម្ពស់គុណភាព និងសុវត្ថិភាពអ្នកជំងឺ និងវគ្គព័ត៌មានវិទ្យា នៃការថែទាំ
- ថ្ងៃទី១៥៖ កិច្ចប្រជុំប្រចាំខែជាមួយ JICA HQ/Cambodia Office
- ថ្ងៃទី១៩៖ កិច្ចប្រជុំសម្រាប់វគ្គបណ្តុះបណ្តាលគ្រូបង្គោល (TOT) ទូទាំងប្រទេស
- ថ្ងៃទី២៤៖ កិច្ចប្រជុំ JCC លើកទី៧
- ថ្ងៃទី២៥៖ អ្នកជំនាញផ្នែកអប់រំការថែទាំ រយៈពេលវែង ចូលរួមជាមួយគម្រោង

**CONTACT INFORMATION**

**Email**: info@jicastrings.com
**Project Office:**

- **Ministry of Health (MoH)**

Department of Human Resource Development (HRDD)
No. 80, Samdach Penn Nouth Blvd (289), Sangkat Beoungkak 2,
Tuol Kork District, Phnom Penh

- **National Maternal and Child Health Center (NMCHC)**

N° 31A, Rue de France (St. 47), Sangkat Sras Chork, Daun Penh District, Phnom Penh

Scan here to find out more about us:
JICA's FB Page
Project's Homepage